**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

-បានឃើញអនុក្រឹត្យលេខ៥១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង

-បានឃើញសេចក្តីសំរេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម

-យោងតាមតំរូវការចាំបាច់

www.pheakdeylaw.com

# សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាមដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **វ៉ា គឹមហុង** | ទេសរដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម | ប្រធាន |
| ២-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម **ម៉ិន សម** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-ឯកឧត្តម **ហួន សាម៉ាង** | អនុប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក **ឈុំ សុជាត** | នាយរងសេនាធិការ និងជានាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ | សមាជិក |
| ៦-ឯកឧត្តម **ឡាំ ជា** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោកជំទាវ **ក្ងួយ ពិសី** | លេខាធិការ នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨-ឯកឧត្តម **ម៉ិន ម៉ាន** | អគ្គនាយកកិច្ចការបច្ចេកទេស និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ឡាវ និងថៃ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩-ឧត្តមសេនីយ៍ឯក**ចាន់ អ៊ាន** | ប្រធាននាយកដ្ឋានកណ្តាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១០-ឧត្តមសេនីយ៍ឯក**ទេព ចំរើន** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ | សមាជិក |
| ១១-ឯកឧត្តម **អភិបាលខេត្ត** | កំពង់ចាម | សមាជិក |
| ១២-ឯកឧត្តម **អភិបាលខេត្ត** | ស្វាយរៀង | សមាជិក |
| ១៣-ឯកឧត្តម **អភិបាលខេត្ត** | ព្រៃវែង | សមាជិក |
| ១៤-ឯកឧត្តម **អភិបាលខេត្ត** | កណ្តាល | សមាជិក |

www.pheakdeylaw.com

| | | |
|---|---|---|
| ១៥-ឯកឧត្តម **អភិបាលខេត្ត** | តាកែវ | សមាជិក |
| ១៦-ឯកឧត្តម **អភិបាលខេត្ត** | កំពត | សមាជិក |
| ១៧-ឯកឧត្តម **អភិបាលខេត្ត** | ក្រចេះ | សមាជិក |
| ១៨-ឯកឧត្តម **អភិបាលខេត្ត** | មណ្ឌលគិរី | សមាជិក |
| ១៩-ឯកឧត្តម **អភិបាលខេត្ត** | រតនគិរី | សមាជិក |
| ២០-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ១ | សមាជិក |
| ២១-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ២ | សមាជិក |
| ២២-ឧត្តមសេនីយ៍ **មេបញ្ជាការ** | យោធភូមិភាគ៣ | សមាជិក |
| ២៣-ឧត្តមសេនីយ៍ទោ **សេង សារី** | នាយសេនាធិការ និងជានាយការិយាល័យការពារព្រំដែនកងទ័ពជើងគោក ក្រសួងការពារជាតិ | សមាជិក |
| ២៤-លោក **អ៊ិត សុត្ថា** | ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ២៥-លោក **ឡាយ វោហារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦-ឧត្តមសេនីយ៍ត្រី **ពេជ្រ ជីវ័ន្ត** | ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧-លោក **ហ្វូ ពេជ្រមាលី** | អនុប្រធាននាយកដ្ឋានច្បាប់និងកុងស៊ុលក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

**ប្រការ២** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម អាចបង្កើតអនុគណៈកម្មការបច្ចេកទេសចំរុះ ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក សំរាប់ធ្វើជាសេនាធិការ ។

**ប្រការ៣** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម មានភារកិច្ចដូចតទៅ :

-អនុវត្តឱ្យបានសំរេចជាស្ថាពរនូវសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និង

សាធារណរដ្ឋសង្គមនិយមវៀតណាម

-រៀបចំចាត់ចែងបែបបទផ្លូវច្បាប់និងបច្ចេកទេសសំរាប់ការងារខ័ណ្ឌសីមានិងបោះបង្គោលព្រំដែន

-រៀបចំចាត់ចែងតួនាទី ភារកិច្ច និងសមាសភាពរបស់អនុគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែន ក្រុមប្រតិបត្តិការចំរុះ និងក្រុមបច្ចេកទេសចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង

-ធ្វើការត្រួតពិនិត្យ ដោះស្រាយបញ្ហា និងឯកសារនានា ដែលក្រុមប្រតិបត្តិការ និង ក្រុមបច្ចេកទេសរាស់វែងជួបប្រទះ លើដីជាក់ស្តែង

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនសំរាប់រាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ៤** : គ្រប់សមាជិកនៃគណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៥** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី នឹងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៦** : គណៈកម្មការចំរុះខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក នឹងត្រូវរំសាយទៅវិញនៅពេលណាដែលការងារអនុវត្តសន្ធិសញ្ញាដូចក្នុងប្រការ៣ ត្រូវបានចប់សព្វគ្រប់ ។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័ន អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៧
-ឯកសារកាលប្បវត្តិ

www.pheakdeylaw.com